ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារ ឆ្នាំ២០២២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អង្គសន្និបាតបានពិនិត្យពិភាក្សាអំពីវឌ្ឍនភាពការងារ ឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពទាំង ៥ ដើម្បីកំណត់ទិសដៅអាទិភាពការងារបន្តសម្រាប់ឆ្នាំ២០២២ ជាពិសេសការចូលរួមក្នុងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

### ក- លទ្ធផលការងារឆ្នាំ២០២១

#### ១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- បើទោះជាស្ថានភាពជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់សេដ្ឋកិច្ច-សង្គមយ៉ាងណា ក៏ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវបានដំឡើងពី ១៩២ដុល្លារអាមេរិក ដល់ ១៩៤ដុល្លារអាមេរិក ក្នុង១ខែសម្រាប់ឆ្នាំ២០២២ បើបូករួមប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ឈ្នួល ចាប់ពី ២១១ដុល្លារអាមេរិក ដល់ ២២២ដុល្លារអាមេរិក ក្នុង១ខែ។
- បានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលទាំង១០ជុំ ដោយបានបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ ដែលព្យួរកិច្ចសន្យាការងារ ដោយសារជំងឺកូវីដ-១៩ សរុបចំនួន ៣៤៧ ៨៤៤នាក់ ស្មើថវិកាប្រមាណ ១១៤,៥៩ប៊ីលានរៀល (ប្រមាណជាង ២៨លានដុល្លារអាមេរិក) ព្រមទាំងបានផ្តល់វគ្គបណ្តុះបណ្តាលជំនាញទន់ផងដែរ។
- បានសម្របសម្រួល និងចូលរួមយុទ្ធនាការជាតិចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាល ដល់កម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស និងប្រជាពលរដ្ឋសរុបប្រមាណ ៥៩ម៉ឺននាក់ ក្នុងនោះក្រោមឆត្រអនុគណៈកម្មការចំពោះកិច្ចបានប្រមាណ ១៣ម៉ឺននាក់ និងក្រោមឆត្រកងយោធពលខេមរភូមិន្ទបានប្រមាណ ៤៦ម៉ឺននាក់។

- បានពង្រឹងការអប់រំផ្សព្វផ្សាយការយល់ដឹងអំពីផលវិបាកដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ និងវិធានការនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញដល់ម្ចាស់រោងចក្រ សហគ្រាស និងបងប្អូនកម្មករនិយោជិត ដើម្បីចូលរួមអនុវត្តសំដៅធានាបាននូវនិរន្តរភាពអាជីវកម្ម/ផលិតកម្ម និងជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិត។
- បានបង្កើតក្រុមការងារដោះស្រាយការរីករាលដាលនៃជំងឺកូវីដ-១៩ តាមបណ្ដារោងចក្រ សហគ្រាស ដោយកំណត់លក្ខណវិនិច្ឆ័យក្នុងការផ្អាក និងបើកឡើងវិញនូវសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយវិធានការរដ្ឋបាល។
- បានដាក់ឱ្យប្រើប្រាស់គោលការណ៍ប្រតិបត្តិស្ដង់ដាស្ដីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាស តាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។
- បានបណ្ដុះបណ្ដាលមន្ត្រីអធិការកិច្ចការងារ ដើម្បីទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ចំនួន ៦វគ្គ សរុបចំនួន ៥២៥នាក់។
- បានដាក់ឱ្យអនុវត្តសាកល្បងនូវរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- បានពង្រឹងការអនុវត្តច្បាប់ស្ដីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមរយៈការចុះធ្វើអធិការកិច្ចការងារនៅតាមរោងចក្រ សហគ្រាស ចំនួន ១ ០៨២លើក ក្នុងនោះ អធិការកិច្ចការងារសាមញ្ញចំនួន ៩៩៣លើក (តាមប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ៩០៦លើក និងអធិការកិច្ចការងារផ្ទាល់ចំនួន ៨៧លើក), អធិការកិច្ចតាមដានការដាក់កំហិតចំនួន ៥សហគ្រាស និងអធិការកិច្ចការងារពិសេស ៨៤សហគ្រាស និងបានដាក់កំហិតចំនួន ៦៥សហគ្រាស និងបានផាកពិន័យចំនួន ៤សហគ្រាស។
- បានផ្សះផ្សាវិវាទការងារសរុបចំនួន ៨៤៩ករណី ដោយទទួលបានលទ្ធផលសះជាចំនួន ៥៥៣ករណី, មិនសះជាចំនួន ២៣០ករណី និងមោឃៈចំនួន ៦៦ករណី ក្នុងនោះ វិវាទការងាររួមចំនួន ១៥៤ករណី និងបានបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលចំនួន ៤៣ករណី ក្នុងនោះ បានចេញសេចក្ដីបង្គាប់ចំនួន ៣៥ករណី សះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាលចំនួន ៥ករណី និងសះជាដោយភាគីទាំងពីរចំនួន ៣ករណី។
- បានអន្តរាគមន៍ដោះស្រាយបញ្ហាកូដកម្មសរុបចំនួន ៦២ករណី ក្នុងនោះ ៩៣,៥៥% ត្រូវបានដោះស្រាយសះជា និងបានធ្វើអន្តរាគមន៍ដោះស្រាយបាតុកម្មចំនួន ១៣ករណី ដោយបានដោះស្រាយសះជា ១០០%។
- បានចុះបញ្ជិកាសហជីពមូលដ្ឋានចំនួន ២៣៦, សហព័ន្ធសហជីពចំនួន ២១, សហភាពសហជីពចំនួន ៤ និងសមាគមនិយោជកចំនួន ១ ដែលគិតត្រឹមឆ្នាំ២០២១ នេះមានអង្គការវិជ្ជាជីវៈសរុបចំនួន ៥ ៧៤៦ ក្នុងនោះសហជីពមូលដ្ឋានចំនួន ៥ ៤៤២, សហព័ន្ធសហជីពចំនួន ២៥២, សហភាពសហជីពចំនួន ៤០ និងសមាគមនិយោជកចំនួន ១២។
- បានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ហើយបានអនុវត្តកិច្ចអន្តរាគមន៍ស្ទូល ដកហូត និងទប់ស្កាត់ ពលកម្មកុមារចំនួន ៣៥០នាក់ (ស្រី ១៥៩នាក់)។

**២-ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ**

- បានបន្តជំរុញការអនុវត្តគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥, ផែនការមេសម្រាប់អភិវឌ្ឍន៍គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ រយៈពេល ៥ឆ្នាំ (២០២១-២០២៥) និងផែនការសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាល

បច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ដល់ភាគីពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍជំនាញនៅកម្ពុជាឱ្យកាន់តែប្រសើរ។

- បានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៣ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ក្រោមប្រធានបទ "TVET ធ្វើឱ្យជំនាញកាន់តែប្រសើរ និងប្រាក់ចំណូលខ្ពស់" ដែលមានអ្នកចូលទាំងផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ប្រមាណ ១២៤ ០០០នាក់ (ស្រី ៣៧ ២០០នាក់) ក្នុងគោលបំណងលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- បានបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត ១, ២ និងកម្រិត៣) ក្នុងវិស័យសំណង់ អគ្គិសនី និងវិស័យកម្មន្តសាលចំនួន ១៦គុណវុឌ្ឍិ លើ ៨មុខរបរ។
- បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform) ដែលគិតត្រឹមឆ្នាំ២០២១ នេះ មានគ្រឹះស្ថាន អ.ប.វ. បានចូលប្រើប្រាស់ចំនួន ៥៧, បានផលិតមាតិកាមេរៀនចំនួន ៤ ១៦៤ និងសិក្ខាកាម សិស្ស និស្សិតបានចូលរៀនចំនួន ៤៩ ៨៧៩នាក់ និងអ្នកទាញកម្មវិធីមកប្រើប្រាស់ជាង ១៥ ០០០នាក់។
- បានរៀបចំវគ្គបណ្តុះបណ្តាលពិសេសលើកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1) ជាពិសេសជូនដល់កម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារ ឬបាត់បង់ការងារដោយសារវិបត្តិកូវីដ-១៩ មានរយៈពេល ៤ខែ សិក្ខាកាមសរុបចំនួន ៦ ៥០០នាក់ (ស្រី ៣ ២៧៦នាក់) ដោយសិក្ខាកាមម្នាក់ទទួលបានប្រាក់ឧបត្ថម្ភចំនួន ២០ម៉ឺនរៀល/១ខែ។
- គ្រឹះស្ថាន អ.ប.វ. ទាំងសាធារណៈ ឯកជន និងអង្គការ/សមាគម បានបណ្តុះបណ្តាលសិក្ខាកាម សិស្ស-និស្សិត និងហ្វឹកហ្វឺនកូនជាងចំនួន ៧៦ ០០៤នាក់ (ស្រី ៣៨ ៩៣១នាក់) ទាំងរយៈពេលខ្លី និងរយៈពេលវែង និងបានធ្វើតេស្តសាកល្បងទទួលស្គាល់ការសិក្សាដែលបានពីមុន (RPL) ចំនួន ២១១នាក់។
- បានចុះបញ្ជីវិស្វករ ៧៤៧នាក់ បើគិតមកទល់បច្ចុប្បន្នមានវិស្វករចុះបញ្ជីសរុបចំនួន ៦ ០០៨នាក់ (ស្រី ២៤០នាក់) ក្នុងនោះ វិស្វករជាតិចំនួន ៥ ៩២៤នាក់ (ស្រី ២៣៨នាក់) និងវិស្វករបរទេសចំនួន ៨៤នាក់ (ស្រី ២នាក់)។
- បានលើកទឹកចិត្តដល់សិស្ស និស្សិត ក្នុងការសិក្សាស្រាវជ្រាវបង្កើតស្នាដៃថ្មី សម្រាប់គាំទ្រដល់វិស័យឧស្សាហកម្ម ដោយបានបង្កើតស្នាដៃរួមមាន៖ Drone, Nursing Assistant Robot និងផលិត Robot សម្រាប់យកទៅចូលរួមកម្មវិធីប្រកួតប្រជែងថ្នាក់ជាតិលើកទី៨ (Robotcon ABU 2021)។
- បានដាក់ឱ្យប្រើប្រាស់គោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.)ឡើងវិញក្នុងបរិបទកូវីដ-១៩។

## ៣-ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស

- បានចុះបញ្ជីសហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធចំនួន ១៣ ៥៧១សហគ្រាស ដែលមានកម្មករនិយោជិតចំនួន ១,៤លាននាក់ ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមជាង ៣,៧ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ហើយបើបូកប្រាក់បញ្ញើពីបងប្អូនពលករនៅក្រៅប្រទេសជាង ៣ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ដែលធ្វើឱ្យប្រាក់ឈ្នួលសរុបមានចំនួនជាង ៦,៧ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។

- បានប្រមូលចុះឈ្មោះអ្នកស្វែងរកការងារចំនួន ៤ ៨២៣នាក់ បានផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារចំនួន ១៣ ៩១៣នាក់ និងជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមមូលដ្ឋានភូមិឃុំ និងតាមរយៈវេទិកាការងារនានា ដែលរៀបចំដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់។
- បាននិងកំពុងអនុវត្តគម្រោងរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិលើកម្មវិធីមុខរបរ និងការងារសមរម្យរបស់យុវជននៅកម្ពុជា (DEY) ដំណាក់កាលទី២ សម្រាប់ជួយដល់យុវជនឱ្យទទួលបានជំនាញតាមគន្លងថ្មីប្រកបដោយគុណភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។
- បានផ្តល់ឱកាសការងារដល់ពលករធ្វើការនៅក្រៅប្រទេសសរុបចំនួន ១ ៣០១ ៦០៩នាក់ ក្នុងនោះប្រទេសថៃមានចំនួន ១ ២២០ ១៩៧នាក់, កូរ៉េ ៤៥ ៨៦៦នាក់, ម៉ាឡេស៊ី ២៣ ០២៧នាក់, ជប៉ុន ១១ ៤៥៣នាក់, សិង្ហបុរី ៨២១នាក់, ហុងកុង ២០២នាក់ និងអារ៉ាប់ប៊ីសាអូឌីត ៤៣នាក់។ បើតាមការប៉ាន់ប្រមាណពីប្រាក់បញ្ញើដែលបងប្អូនពលករបានផ្ញើជូនក្រុមគ្រួសារក្នុងមួយឆ្នាំៗ ប្រហែល ៣ប៊ីលានដុល្លារអាម៉េរិក ដែលតាមរយៈទឹកប្រាក់ទាំងនេះបានចូលរួមចំណែកជំរុញដល់កំណើនសេដ្ឋកិច្ចជាតិ ហើយជីវភាពរស់នៅរបស់ក្រុមគ្រួសារពលករកាន់តែប្រសើរឡើងផងដែរ។
- បានបន្តជំរុញការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងការការពារ និងការលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍បងប្អូនពលករទាំងការទទួលបានកិច្ចគាំពារសង្គមក្នុងពេលបម្រើការងារ និងពេលត្រឡប់មកស្រុកកំណើតវិញ។

**៤-ការអភិវឌ្ឍរបបសន្តិសុខសង្គម**

- បានចុះបញ្ជិការោងចក្រ សហគ្រាស ផ្នែកហានិភ័យការងារ សរុបចំនួន ១៧ ១០៨សហគ្រាស មានកម្មករនិយោជិតចំនួន ២ ២៧៦ ១៧៣នាក់ (ស្រី ១ ៤៩២ ៨៩១នាក់) និងបានផ្តល់តាវកាលិកចំនួន ៩ ១៩៤ឯកសារ ដែលមានជនរងគ្រោះចំនួន ៥ ៨២០នាក់ (ស្រី ២ ៩៩៦នាក់)។
- បានដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ កាលពីខែមករា ឆ្នាំ២០២១ កន្លងទៅ ដោយបានចុះបញ្ជិកាក្រសួង ស្ថាប័ន ចំនួន ៣៥ មានមន្ត្រីសាធារណៈសរុបចំនួន ២៤៨ ៨០០នាក់ (ស្រី ១០៣ ៣០២នាក់)។
- បានចុះបញ្ជិការោងចក្រ សហគ្រាស ផ្នែកថែទាំសុខភាព សរុបចំនួន ១៤ ៤៧៩ សហគ្រាស មានកម្មករនិយោជិតចំនួន ២ ២៧៦ ១៧៣នាក់ (ស្រី ១ ៤៩២ ៨៩១នាក់) និងបានផ្តល់ការពិនិត្យព្យាបាលជំងឺជូនដល់កម្មករនិយោជិត ដោយមិនបង់ប្រាក់សរុបចំនួន ១ ៨៩៦ ៨៥៨ ដង.នាក់។
- បានចុះបញ្ជីផ្នែកថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនបានចំនួន ៣៨ ក្រសួង ស្ថាប័ន មានសមាជិកសរុបចំនួន ៤១៧ ៥៤៣នាក់ (ស្រី ១២៥ ១៩៩នាក់) និងមានអ្នកទៅប្រើសេវាចំនួន ២៥៨ ១៩១ដង.នាក់។
- បានផ្តល់របបសន្តិសុខសង្គមដល់ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៩៤៤សហគ្រាស មានកម្មករសរុបចំនួន ៩៤ ៣៧៨នាក់ (ស្រី ២០ ៣៦៥នាក់)។
- បានពង្រីកវិសាលភាពចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី ខេត្ត ចំនួន ១ ៤៥៦ រួមមានមន្ទីរពេទ្យថ្នាក់ជាតិចំនួន ៦ មន្ទីរពេទ្យបង្អែកចំនួន ១១៨ មណ្ឌលសុខភាពចំនួន ១ ២២០ និងមន្ទីរពេទ្យឯកជនចំនួន ១១២ ដើម្បីឱ្យកម្មករទទួលបានសេវាដែលនៅជិតកន្លែងការងារ និងលំនៅដ្ឋាន។

- បានបន្តផ្តល់ប្រាក់ឧបត្ថម្ភស្ត្រីក្រោយពេលសម្រាលកូនចំនួន ៦៥ ៨៧១នាក់ ស្មើនឹងចំនួនកូន ៦៦ ៣៣៥នាក់ ដែលគិតជាទឹកប្រាក់អស់ប្រមាណ ២៦,៥៣ប៊ីលានរៀល (ប្រមាណ ៦,៤៧លានដុល្លារអាម៉េរិក) បើគិតចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២១ ស្ត្រីសម្រាលកូនសរុបមានចំនួន ២៨២ ០៧៣នាក់ ចំណាយថវិកាអស់ប្រមាណ ១១៣,៦១ប៊ីលានរៀល (ប្រមាណ ២៧,៧១លានដុល្លារអាម៉េរិក)។
- បាននិងកំពុងរៀបចំដាក់ឱ្យអនុវត្តរបបប្រាក់សោធន សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជនដែលគ្រោងនឹងអនុវត្តក្នុងឆ្នាំ២០២២ នេះ។
- បាននិងកំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធន ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធននិវត្តន៍។

## ៥-ការពង្រឹងសេវាគាំទ្រទូទៅ

- បានបន្តចូលរួមអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ សំដៅកែលម្អគុណភាពសេវាសាធារណៈរបស់ក្រសួងឱ្យកាន់តែប្រសើរឡើង ព្រមទាំងបានពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមន្ត្រីរាជការឱ្យឆ្លើយតបនឹងសំណូមពរ និងតួនាទីភារកិច្ចរបស់ក្រសួង តាមរយៈកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព និងវិក្រឹត្យការមន្ត្រីគ្រប់ផ្នែក និងគ្រប់កម្រិត។
- បានចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ដោយផ្តែកលើទស្សនទាន "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ" ព្រមទាំងអនុវត្តតាមក្របខ័ណ្ឌនៃកំណែទម្រង់ និងគោលនយោបាយផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញ។
- បានចូលរួមក្នុងក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានដើម្បីសិក្សារៀបចំច្រកចេញចូលដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។
- បានបន្តពង្រឹងកិច្ចសហការល្អជាមួយអង្គការអន្តរជាតិខាងការងារ (ILO) តាមរយៈការបន្តអនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ ការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័ន និងអនុវត្តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការអន្តរជាតិខាងការងារពាក់ព័ន្ធនឹងសេរីភាពអង្គការវិជ្ជាជីវៈ។
- បានអនុវត្តអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ទាំង១០ចំណុច របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ប្រកបដោយជោគជ័យ៖
  - ១-គ្រប់រោងចក្រទាំងអស់ត្រូវអនុវត្តប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០២២ ចំនួន ១៩៤ដុល្លារអាម៉េរិក និងបើកប្រាក់ឈ្នួល ២ដងក្នុងមួយខែ។
  - ២-កម្មករនិយោជិតទទួលបានការពិនិត្យព្យាបាលជំងឺ ដោយមិនបង់ប្រាក់។
  - ៣-កម្មការិនីទទួលបានប្រាក់ឈ្នួល ១២០% និងឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូនបានផ្តល់ប្រាក់ឈ្នួលដល់កម្មការិនីសម្រាលកូន។
  - ៤-ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីក្រោយពេលសម្រាលកូន ដោយផ្តល់ជូនកូនចំនួន ១នាក់ ថវិកា ៤០ម៉ឺនរៀល, កូនចំនួន ២នាក់ ថវិកា ៨០ម៉ឺនរៀល និងកូនចំនួន ៣នាក់ ថវិកា ១,២ លានរៀល ព្រមទាំងទទួលបានថវិកាបន្ថែមចំនួន ៥លានរៀល ពី សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ផ្ទាល់។
  - ៥-និយោជកបានបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករនិយោជិត។

៦-ស្ថាប័នពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ បន្តត្រួតពិនិត្យថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនីនៅតាមផ្ទះជួល និងជំរុញការតភ្ជាប់បណ្តាញអគ្គិសនី និងទឹកស្អាតនៅតាមតំបន់ផ្ទះជួលរបស់កម្មករនិយោជិត។

៧-ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ទទួលបានការអនុម័ត និងដាក់ឱ្យប្រើប្រាស់ដើម្បីអនុវត្តផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត និងផ្នែករបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ។

៨-អនុវត្តច្បាប់ស្តីពីការងារ ដើម្បីកំណត់ការបើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត ៦ខែម្តង។

៩-បានសហការជាមួយក្រសួងពាក់ព័ន្ធ បន្តដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត ការរៀបចំកែសម្រួលមធ្យោបាយដឹកជញ្ជូន និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក។

១០-បានពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ និងផលប្រយោជន៍ពលករ ដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

## ខ. ទិសដៅអនុវត្តបន្តឆ្នាំ២០២២

១-បន្តអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង ១០ ចំណុចរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

២-បន្តខិតខំអនុវត្តឱ្យសម្រេចជោគជ័យ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់នូវយុទ្ធសាស្ត្រអាទិភាពទាំង ៥ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ព្រមទាំងគោលនយោបាយជាតិពាក់ព័ន្ធ។

៣-ជំរុញការអនុវត្តយន្តការអធិការកិច្ចការងារតាមប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា និងដាក់ឱ្យដំណើរការក្រុមអធិការកិច្ចអន្តរស្ថាប័ន សំដៅធានាបាននូវវប្បធម៌អនុលោមភាពនៅតាមសហគ្រាស។

៤-បន្តពង្រឹងយន្តការដោះស្រាយវិវាទការងារឱ្យទទួលបានអត្រាសះជាឱ្យកាន់តែខ្ពស់ សំដៅឆ្លើយតបនឹងតម្រូវការភាគីវិវាទ និងដាក់ឱ្យដំណើរការសាកល្បងការដោះស្រាយវិវាទបុគ្គល ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងពង្រឹងការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈឱ្យបានត្រឹមត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តជាតិ ជាធរមាន និងអនុសញ្ញាអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័ន។

៥-បន្តពង្រឹងអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា សំដៅអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់តាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល បទបញ្ជារបស់រាជរដ្ឋាភិបាល និងផែនការស្តីពីការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញាសម្រាប់ ឆ្នាំ២០២០-២០២៤ ដើម្បីធានាសន្តិភាព ស្ថិរភាពនយោបាយ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ។

៦-បន្តប្រែក្លាយរោងចក្រ សហគ្រាស មួយជាសហគមន៍សុខសាន្តមួយរបស់កម្មករនិយោជិតដែលពោរពេញដោយសមត្ថភាព លក្ខខណ្ឌការងារល្អប្រសើរ ផលិតភាព ឥរិយាបថការងារ ការទទួលខុសត្រូវសង្គម និងមានសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ដោយក្រសួងនឹងផ្តល់ជាវិញ្ញាបនបត្របញ្ជាក់ជូនរោងចក្រ សហគ្រាស ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខណវិនិច្ឆ័យ។

៧-បន្តសិក្សាស្រាវជ្រាវ សហការ និងពិភាក្សាជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាព និងសុខភាពការងារ គោលនយោបាយជាតិស្តីពីសុវត្ថិភាព និងសុខភាពការងារ ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងពិនិត្យមើលលើការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ច្បាប់ស្តីពី

សហជីព ច្បាប់ស្ដីពីរបបសន្តិសុខសង្គម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីស្របតាមការវិវត្តនៃសេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន។

៨-បន្តពង្រឹងយន្តការក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដើម្បីធានាបាននូវការចរចាប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗប្រកបដោយភាពសុខដុមរមនា និងអាចទទួលយកបានពីគ្រប់ភាគី ព្រមទាំងសិក្សាពីលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃប្រាក់ឈ្នួលអប្បបរមា។

៩-បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមគាំទ្រដល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព និងតាមតម្រូវការជាក់ស្តែងនៃសភាពការណ៍ជាពិសេស ក្នុងដំណាក់កាលចាំបាច់ត្រូវបង្កើនសមត្ថភាពជំនាញ (Upskilling) និងបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) នៃកម្លាំងពលកម្មដែលកំពុងស្ថិតនៅក្នុងទីផ្សារការងារស្រាប់ និងឱកាសការងារថ្មីៗ។

១០-ពង្រឹង និងពង្រីកវិសាលភាពក្នុងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ ព្រមទាំងការផ្តល់ប្រឹក្សាយោបល់ការងារ អាជីព ដើម្បីធ្វើការផ្គូផ្គង និងឆ្លើយតបបាននូវតម្រូវការកម្លាំងពលកម្មតាមទីផ្សារការងារ ដោយបង្កើនភាពជាដៃគូជាមួយវិស័យឯកជន។

១១-បន្តខិតខំដោះស្រាយបញ្ហាផ្គត់ផ្គង់កង្វះកម្លាំងពលកម្មដល់រោងចក្រ សហគ្រាស ដែលកំពុងខ្វះកម្លាំងពលកម្ម តាមរយៈការបន្តលើកកម្ពស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងទីភ្នាក់ងារជ្រើសរើសឯកជនផ្តល់សេវារកការងារឱ្យធ្វើក្នុងស្រុក និងក្រៅប្រទេស។

១២-បន្តបើកវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិការងារ ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងវិស័យការងារដើម្បីឱ្យក្លាយជាអធិការការងារ អធិការពេទ្យការងារ អភិបាលការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារ និងផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គការវិជ្ជាជីវៈ សិស្ស និស្សិត និងអ្នកពាក់ព័ន្ធឱ្យយល់ដឹងពីច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ។

១៣-បន្តពង្រឹងការងារចុះអធិការកិច្ចអន្តរក្រសួង និងធ្វើទំនើបកម្មការធ្វើអធិការកិច្ចការងារ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា និងកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាស ជាមូលដ្ឋានក្នុងការធ្វើអធិការកិច្ច និងការធ្វើអធិការកិច្ចការងារលើរោងចក្រ សហគ្រាស ចំនួន ១ លើក/ឆ្នាំ ហើយធានាប្រសិទ្ធភាព គុណភាព និងតម្លាភាពក្នុងការផ្តល់សេវា ដោយដាក់រាល់សេវាទាំងអស់របស់ក្រសួងទៅក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាន។

១៤-បន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវអភិក្រមទាំង៥ គឺ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់" និងបាវចនា២ "កែទម្រង់ផ្ទៃក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ" របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៩រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២